Declassified to Public
27 June 2019

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 22 / 10 / 2015
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង - សម្ងាត់

ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥

**ជូនចំពោះ៖** គ្រប់ភាគីទាំងអស់ក្នុងសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) សុំស្តាប់សក្ខីកម្មសាក្សីបន្ថែមមួយរូបលើអង្គហេតុស្តីពីការដ្ឋានការងារទំនប់ត្រពាំងថ្ម

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើរបស់មេធាវីការពារក្តី នួន ជា ដែលបានដាក់នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៥ សុំស្តាប់សក្ខីកម្មសាក្សី 2-TCW-996 បន្ថែមមួយរូបទៀត ទាក់ទងនឹងអង្គហេតុស្តីពីការដ្ឋានការងារទំនប់ត្រពាំងថ្ម ("សំណើសុំ" ឯកសារ E368)។ មេធាវីការពារក្តី នួន ជា សន្និដ្ឋានថា សាក្សី 2-TCW-996 អាចផ្តល់ភ័ស្តុតាងសំខាន់ និងស៊ីសង្វាក់គ្នាជាមួយនឹងរឿងក្តីរបស់មេធាវីការពារក្តី ជាពិសេស បញ្ហានានាទាក់ទងនឹងការរៀបចំចាត់តាំងថ្នាក់ដឹកនាំនៅតំបន់ ៥ ក្នុងភូមិភាគពាយ័ព្យ ជាទីតាំងដែលទំនប់ត្រពាំងថ្មស្ថិតនៅ ព្រមទាំងខ្សែសង្វាក់នៃការបញ្ជា និង លក្ខខណ្ឌការងារនៅទំនប់នេះ (ឯកសារ E368 កថាខណ្ឌ ៣, ៦)។ មេធាវីការពារក្តី ខៀវ សំផន គាំទ្រសំណើសុំនេះ (ប្រតិចារឹកសវនាការ ថ្ងៃទី ៣០ ខែ កញ្ញា ទំព័រ ៨៤)។ សហព្រះរាជអាជ្ញាពុំជំទាស់ទៅនឹងសំណើសុំនេះទេ ហើយសន្និដ្ឋានថា សក្ខីកម្មរបស់សាក្សី 2-TCW-996 អាចមានប្រយោជន៍ក្នុងការបញ្ជាក់បំភ្លឺលើបញ្ហានានាទាក់ទងនឹងលក្ខខណ្ឌការងារនៅទំនប់នេះ និង ការបះបោររបស់កម្មាភិបាលភូមិភាគពាយ័ព្យ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏ពុំជំទាស់ដែរ (ប្រតិចារឹកសវនាការ ថ្ងៃទី ៣០ ខែ កញ្ញា ទំព័រ ៨៣-៨៤)។

២. នៅថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៥ អង្គជំនុំជម្រះបានផ្ញើជាលក្ខណៈក្រៅផ្លូវការនូវអនុស្សរណៈមួយច្បាប់ទៅភាគីពាក់ព័ន្ធ (អនុស្សរណៈត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងនៅថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ E372) ដោយអង្គជំនុំជម្រះយល់ព្រមតាមសំណើរបស់មេធាវីការពារក្តីសុំស្តាប់សក្ខីកម្មសាក្សី 2-TCW-996 ហើយនឹងដាក់សំអាងហេតុនៃការសម្រេចនេះនៅពេលក្រោយ។ នៅពេលនេះ អង្គជំនុំជម្រះសូមបង្ហាញសំអាងហេតុរបស់ខ្លួនលើសេចក្តីសម្រេចនេះ។

៣. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលអនុវត្តចំពោះការកោះហៅ និង ការស្តាប់សក្ខីកម្មសាក្សីថ្មី (ឯកសារ E307/1) នៅគ្រប់ដំណាក់កាលនៃការជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកភស្តុតាងទាំងអស់ដែលខ្លួនយល់ឃើញថាអាចជួយដល់ការបញ្ជាក់ការពិតក្នុងករណីដែលភស្តុតាងទាំងនោះបំពេញលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង រួមទាំងបទដ្ឋាន*ឋឋឋ*ស្តីពីភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និង យថាភាព (ឯកសារ E319/7 កថាខណ្ឌ ៨)។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងក៏តម្រូវឱ្យភាគីដែលស្នើសុំទទួលយកភស្តុតាងថ្មីដាក់សំណើសុំ ដោយមានសម្អាងហេតុផងដែរ។ ភាគីស្នើសុំត្រូវធ្វើយ៉ាងណាឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ភស្តុតាងស្នើសុំនោះពុំអាចរកបាននៅមុនពេលបើកការជំនុំជម្រះ ឬ មិនអាចរកឃើញ បើទោះជាបានប្រឹងប្រែងយ៉ាងសមស្រប រួចហើយក៏ដោយ។ ទោះបីជាយ៉ាងនេះក្តី នៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះបានទទួលយកភស្តុតាងដែលពុំបានបំពេញនូវលក្ខខណ្ឌនេះ រួមទាំងក្នុងករណីដែលភស្តុតាងជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងសម្ភារៈដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ និង ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យវាយតម្លៃប្រភពទាំងអស់នោះរួមគ្នា ក្នុងករណីឯកសារស្នើសុំជាឯកសារដោះបន្ទុក និង តម្រូវឱ្យធ្វើការវាយតម្លៃដើម្បីជៀសវាងកុំឱ្យមានកំហុសក្នុងការស្វែងរកយុត្តិធម៌ ឬ ក្នុងករណីដែលភាគីផ្សេងទៀតពុំបានជំទាស់ទៅនឹងភស្តុតាងទាំងនោះ (ឯកសារ E276/2 កថាខណ្ឌ ២ ដែលយោងលើឯកសារ E190 និង ឯកសារ E172/24/5/1 ឯកសារ E260 កថាខណ្ឌ ៥)។

៤. អង្គជំនុំជម្រះសាលាដំបូងរម្លឹកឡើងវិញថា កិច្ចដំណើរការនីតិវិធីសវនាការមួយប្រកបដោយយុត្តិធម៌ និង ចំពោះមុខ គឺត្រូវរក្សាតុល្យភាពរវាងសិទ្ធិរបស់ភាគីនានា និង ភាពចាំបាច់ត្រូវបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងរយៈពេលមួយសមស្រប (ឯកសារ E312 កថាខណ្ឌ ២២)។

៥. ជាបញ្ហាបឋម អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សំណើសុំនេះពុំបានដាក់ទាន់ពេលវេលាកំណត់នោះទេ។ ទោះបីជាសាក្សី 2-TCW-996 បានផ្តល់កិច្ចសម្ភាសន៍ដល់មជ្ឈមណ្ឌលឯកសារកម្ពុជានៅប្រហែលជាពេលចាប់ផ្តើមការជំនុំជម្រះក្នុងខែ កក្កដា ឆ្នាំ ២០១១ ហើយវាពុំអាចឱ្យមេធាវីការពារក្តី នួន ជា រកបាននៅពេលនោះក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា ចម្លើយនេះបានមានអត្ថិភាពជាសារធារណៈចាប់តាំងពីពេលនោះមកម្ល៉េះ។ មេធាវីការពារក្តី នួន ជា តវ៉ាថា ធនធានមានកម្រិតរបស់ខ្លួន "ពុំអាចឱ្យខ្លួនស្រាវជ្រាវ វិភាគ និង កំណត់គ្រប់ភស្តុតាងទាំងឡាយដែលអាចជាភស្តុតាងដោះបន្ទុកដែលបានមានអត្ថិភាពជាសាធារណៈទេ"។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ចម្លើយនេះបានដាក់នៅក្នុងសំណុំរឿងនៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៤ ហើយក្រោយមកបានទទួលជាឯកសារចំណាត់ប្រភេទ E3 (ឯកសារ E3/9076)។ ម្យ៉ាងវិញទៀត កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី 2-TCW-996 ជាមួយនឹង ក.ស.ច.ស នៅក្នុងសំណុំរឿង ០០៤ (ឯកសារ E319/19.3.18) ត្រូវបានដាក់បង្ហាញនៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥ ហើយក្រោយមកត្រូវបានទទួលយកនៅក្នុងសំណុំរឿង ០០២ (សូមមើលឯកសារ E319/22/1)។ មេធាវីការពារក្តីសន្និដ្ឋានថា កាលវិភាគដ៏មមាញឹករបស់ខ្លួនបានធ្វើឱ្យខ្លួនពុំមានលទ្ធភាពពិនិត្យមើលឡើងវិញនូវចម្លើយសាក្សីទាំងនេះឱ្យបានទាន់ពេលវេលា រហូតដល់ពេលខ្លួនត្រៀមរៀបចំសម្រាប់ការជំនុំជម្រះលើអង្គហេតុនៃការដ្ឋានការងារទំនប់ត្រពាំងថ្ម (ឯកសារ E368 កថាខណ្ឌ ១៣-១៤)។ ដោយកត់សម្គាល់ឃើញថា ចម្លើយនៃមជ្ឈមណ្ឌលឯកសារកម្ពុជា និង កំណត់ហេតុនៃការស្តាប់ចម្លើយក្នុងសំណុំរឿង ០០៤ មាននៅក្នុងសំណុំរឿងអស់រយៈពេល ៩ ខែ និង ៦ ខែ ជាបន្តបន្ទាប់គ្នា នៅមុនពេលដាក់សំណើសុំនេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មេធាវីការពារក្តី នួន ជា គួរតែបានដឹងយ៉ាងសមហេតុផលអំពីភាពពាក់ព័ន្ធទៅនឹងសាក្សី 2-TCW-996 ហើយខកខានមិនបានខិតខំប្រឹងប្រែងឱ្យបានសមស្របក្នុងការដាក់សំណើសុំនេះ។

៦. ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា វាជាផលប្រយោជន៍យុត្តិធម៌ដែលត្រូវស្តាប់សក្ខីកម្មសាក្សី 2-TCW-996។ សាក្សី 2-TCW-996 បានគ្រប់គ្រងផ្ទាល់លើការងារនៅក្នុងកងចល័តរបស់ តា វ៉ាល់ នៅការដ្ឋានទំនប់ត្រពាំងថ្មក្នុងឆ្នាំ ១៩៧៧ (សូមមើលឯកសារ E3/9076 ERNs 00731156-57, ឯកសារ E319/19.3.18 ERNs 01044799)។ ក្រោយពីពិនិត្យមើលទៅលើតួនាទីរបស់គាត់ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សាក្សី 2-TCW-996 អាចផ្តល់ព័ត៌មានមានតម្លៃអំពីបញ្ហានានាទាក់ទងនឹងការរៀបចំចាត់តាំងថ្នាក់

ដឹកនាំនៅតំបន់ ៥ ក្នុងភូមិភាគពាយ័ព្យ ខ្សែសង្វាក់នៃការបញ្ជានៅទំនប់ត្រពាំងថ្ម និង លក្ខខណ្ឌការងារនៅទីនោះ ជាពិសេស របបអាហារ និង ការថែទាំផ្នែកវេជ្ជសាស្ត្រ (សូមមើលឯកសារ E3/9076 ERNs 00731157-62, 67-70, ឯកសារ E319/19.3.18 ERNs 01044800-5)។ សាក្សី 2-TCW-996 ក៏អាចជួយបញ្ជាក់បំភ្លឺដល់អង្គជំនុំជម្រះលើការបះបោររបស់កម្មាភិបាលភូមិភាគពាយ័ព្យ និង ផែនការរបស់ពួកគេក្នុងការផ្តួលរំលំរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និង ការប្រព្រឹត្តលើអតីតទាហាន លន់ នល់ នៅការដ្ឋានទំនប់ត្រពាំងថ្មផងដែរ (សូមមើលឯកសារ E3/9076 ERNs 00731169-70)។

៧. អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា លក្ខខណ្ឌតម្រូវនៅក្នុងវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុងបានបំពេញ ហើយយល់ព្រមតាមសំណើសុំស្តាប់សក្ខីកម្មសាក្សី 2-TCW-996 នៅក្នុងសំណុំរឿង ០០២/០២ បន្ថែមមួយរូបទៀត។

៨. អនុស្សរណៈនេះ គឺជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះចំពោះឯកសារ E368។